# III ការងារបណ្ដាក្រសួង

## ១—ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សារាចរណែនាំ

រាជធានីភ្នំពេញ ,ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៦

**សារាចរណែនាំលេខ ០១២ សណន.សហវថ**

**ស្តីអំពីវិធានការដាក់ស្តែងមួយចំនួនសំរាប់**

**ការអនុវត្តថវិការដ្ឋ ក្នុងជំហានទី ២**

**នៃកំណែទម្រង់ ហិរញ្ញវត្ថុសាធារណៈ**

ផ្អែកតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ និង អនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៨១ អនក្រ.បក ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត - រាជធានីភ្នំពេញ និង អង្គការសាធារណៈរដ្ឋបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញជាប្រកាស និង សារាចរណែនាំ[illegible] បន្ទាប់មានដូចតទៅនេះ :

១ - ប្រកាសលេខ ០០៥ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។

២ - សារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីអំពីរដ្ឋនេយ្យបំណុល ។

៣ - សារាចរណែនាំលេខ ០០៣ សហវ.ម ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីអំពី រដ្ឋនេយ្យបុរេប្រទាន ។

៤ - សេចក្តីណែនាំលេខ ០០៤ សហវ.ម ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ភ្នាក់ងារបើក ផ្តល់ ។

៥ - សារាចរណែនាំលេខ ០០៦ សហវ.ម ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៦ ស្តីអំពីទម្រង់ ការទូទៅដើម្បីអនុវត្តថវិការដ្ឋទៅតាមបទបញ្ជាថ្មី ស្តីពីកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និង គណនេយ្យ ។

៦ - សារាចរណែនាំលេខ ០០៧ សហវ.ម ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៦ ស្តីអំពីវិន័យ និង ទូលទាត់ណោទាន ។

៧ - សេចក្តីណែនាំលេខ ០០៩ សហវ.ម ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៦ ស្តីអំពីនីតិវិធី និងបែបបទចំណាយថវិកា ។

ដើម្បីធានាសុពលភាពនៃដំណើរការអនុវត្តថវិកា ប្រព្រឹត្តទៅអោយកាន់តែទទួលបានលទ្ធផលល្អ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានវិធានការណ៍ជាក់ស្តែងមួយចំនួនចំពោះមុខដូចតទៅនេះ :

**១/- ការធ្វើអាណត្តិកិច្ចចំណាយ :**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ កំណត់យកថ្ងៃ ០១ ខែ កក្កដា ឆ្នាំ ១៩៩៦ ជាថ្ងៃចាប់ផ្តើមការអនុវត្តន៍កិច្ចប្រតិបត្តិការចំណូល ចំណាយថវិការដ្ឋតាមគោលការណ៍កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈជំហានទី ២ ដូច្នេះរាល់សំណុំលិខិតស្នើសុំធានារបស់ក្រសួងស្ថាប័ន ដែលបានបញ្ជូនមកដល់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មុនរយៈពេលកំណត់ខាងលើ និង រាល់សំណើធានារបស់ក្រសួងស្ថាប័ន ដែលបញ្ជូនមកនៅចន្លោះពេលថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៦ រហូតដល់ថ្ងៃដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានធ្វើប្រកាសតែងតាំងមន្ត្រីធ្វើការងារអភិបាលហិរញ្ញវត្ថុនោះ ការធ្វើអាណត្តិកិច្ចចំណាយ ( Mandat ) គឺបន្តធ្វើនៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ( នាយកដ្ឋានថវិកា ) ។

ក្រោយពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានចេញប្រកាសតែងតាំង មន្ត្រីធ្វើការងារអភិបាលហិរញ្ញវត្ថុ ក្រសួងស្ថាប័នសាមីមានភារៈទទួលខុសត្រូវធ្វើអាណត្តិកិច្ចចំណាយ ដោយផ្អែកតាមស្មារតីនៃ សេចក្តីណែនាំលេខ ០០៩ សហវ.ម ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៦ ស្តីអំពីនីតិវិធី និង បែបបទចំណាយថវិកា ។

ក្រសួងស្ថាប័នត្រូវធ្វើអាណត្តិកិច្ចចំណាយចំនួន ០៧ ច្បាប់

– ទុកឯកសារនៅក្រសួងស្ថាប័ន ១ ច្បាប់
– មន្ត្រីធ្វើការងារអភិបាលហិរញ្ញវត្ថុ ១ ច្បាប់
– នាយកដ្ឋានថវិកា ( ក្រោយពេលចុះទិដ្ឋាការរបស់មន្ត្រីធ្វើការងារអភិបាលហិរញ្ញវត្ថុរួច ) ១ ច្បាប់
– រតនាគារជាតិ ៤ ច្បាប់

**២/- ការពិនិត្យផ្តល់ឥណទានចំណាយ :**

រាល់សំណើឥណទានរបស់ក្រសួងស្ថាប័ន ជាប្រាក់រៀលក្តី ជារូបិយប័ណ្ណក្តី ជាដំបូងបង្អស់ត្រូវឆ្លងកាត់មន្ត្រីធ្វើការងារអភិបាលហិរញ្ញវត្ថុ ។ ចំពោះសំណើឥណទានសាងសង់ទព្វសំភារៈ និង ឥណទានជារូបិយប័ណ្ណ មន្ត្រីធ្វើការងារអភិបាលហិរញ្ញវត្ថុ ត្រូវបញ្ជូនមកនាយកដ្ឋានពាក់ព័ន្ធ ( នាយកដ្ឋានហិរញ្ញវត្ថុ ក្រៅប្រទេស នាយកដ្ឋានគ្រប់គ្រងទុនវិនិយោគ និង ស្ថាបនាមូលដ្ឋាន ) ដើម្បីពិនិត្យអោយបានទាន់ពេលវេលា ។

ដើម្បីប្រតិបត្តិអោយមានប្រសិទ្ធភាពតាមស្មារតីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈក្នុងជំហានថ្មីនេះ ការផ្សារភ្ជាប់ពីភាពជាក់ស្តែងទៅនឹងស្ថានភាពការណ៍សេដ្ឋកិច្ចហិរញ្ញវត្ថុ និងថវិកាពេលបច្ចុប្បន្នគឺជាប្រការចាំបាច់បំផុត ។ ពិនិត្យលើតុល្យភាពរវាងស្ថានភាពចំណូលចំណាយ ថវិការដ្ឋទៅនឹងស្ថានភាព ចំណូល ចំណាយសាច់ប្រាក់នៃរតនាគារជាតិ ឃើញថាការបាត់តុល្យភាពជាប្រចាំ នាំមកនូវកង្វះសាច់ប្រាក់សំរាប់ចំណាយ និង ការទូទាត់ក្នុងដំណើរការចំណាយរដ្ឋបាល ។

វិធានការណ៍ចំពោះមុខសំរាប់ដោះស្រាយ និនភាពសាច់ប្រាក់នៃរតនាគារជាតិគឺវិធីតុល្យភាព ចំណូល ចំណាយថវិកាដោយឈរលើគោលការណ៍ មានចំណូលទើបចំណាយ ។

ផ្តើមចេញពីនេះ រាល់សំណើឥណទានចំណាយដំណើរការរដ្ឋបាល សំភារៈជួសជុលតូចនិង សាងសង់ទព្វសំភារៈ ក្រៅពីជំពូក ១០ របស់ក្រសួងស្ថាប័នជាប្រាក់រៀលក្តីជារូបិយប័ណ្ណក្តីដែលលើសពី កំរិតកំណត់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនោះមន្ត្រីធ្វើការងារអភិបាលហិរញ្ញវត្ថុ រឺ នាយកដ្ឋាន ហិរញ្ញវត្ថុក្រៅប្រទេស រឺ នាយកដ្ឋានគ្រប់គ្រងទុនវិនិយោគស្ថាបនាមូលដ្ឋានត្រូវសុំសេចក្តីសំរេចពីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុដោយឆ្លងកាត់នាយកដ្ឋានថវិការដ្ឋ ដើម្បីពិនិត្យតុល្យភាពចំណូលចំណាយថវិកា សំដៅអោយអាណត្តិកិច្ច ចំណាយ ដែលបញ្ជូនដល់រតនាគារជាតិធានាមានសាច់ប្រាក់ ។

ចំពោះសំណើឥណទានចំណាយរបស់ក្រសួងស្ថាប័ន សំរាប់ផ្តល់ឥណទានបន្ថែមទៅអោយមន្ទីរ ជំនាញជាខ្សែបណ្តោយរបស់ខ្លួននៅខេត្ត - ក្រុង ត្រូវមានការយល់មតិពីមន្ត្រីធ្វើការងារអភិបាលហិរញ្ញវត្ថុជាមុន ទើបបញ្ជូនមកនាយកដ្ឋានថវិកាដើម្បីពិនិត្យ និងធ្វើប្រកាសផ្ទេរឥណទាន ។

៣/- ការពិនិត្យលើសំណើនិយ័តភាពឥណទាន :

នាយកដ្ឋានថវិការដ្ឋជាអង្គភាពទទួលខុសត្រូវលើការពិនិត្យរាល់សំណើនិយ័តភាពឥណទានរបស់ក្រសួងស្ថាប័ន និង មន្ទីរជំនាញនានានៅខេត្ត - ក្រុង ។ ដោយឡែករាល់សំណើនិយ័តភាពថវិកា របស់ក្រសួងស្ថាប័ន ត្រូវឆ្លងការរួមគំនិតពីមន្ត្រីធ្វើការងារអភិបាលៈហិរញ្ញវត្ថុជាមុនសិន ។

វិធានការណ៍បន្ថែមជាច្រើនទៀត នឹងត្រូវដាក់ចេញជាបន្តបន្ទាប់ ក្រោមរូបភាពជាប្រកាស សេចក្តីណែនាំ រឺ លិខិតបទដ្ឋានផ្សេងៗ ដើម្បីបំពេញបន្ថែមអោយការអនុវត្តថវិការដ្ឋក្នុងកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ អោយទទួលបានលទ្ធផលល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់ ។

គ្រប់ក្រសួងស្ថាប័នទាំងអស់ ត្រូវយកចិត្តទុកដាក់អនុវត្តអោយបានត្រឹមត្រូវទៅតាមនីតិវិធី និង បរិបថចំណាយថវិកា ក្នុងករណីមានបញ្ហាស្មុគ្រស្មាញ ត្រូវមកទំនាក់ទំនងដោះស្រាយជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និ ត្រា

**គាត ឈន់**

* * *

## ២—ដីកាការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

**ប្រកាសលេខ ៤២៩ ឧក. ប្រក ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៦**

**ប្រការ ១** : អនុញ្ញាតអោយលោក **ឈួន ហ៊ីម** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣២៤៤៣២ ភ.ព ចុះថ្ងៃទី ០៦–៤–៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៤ ផ្លូវលេខ ១៦២ សង្កាត់ ផ្សារដេប៉ូទី១ ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញបើកដំណើរការសហគ្រាសផលិតគ្រឿងសង្ហារឹម នៅក្នុងទីតាំងភូមិក្រាំងល្ពង ឃុំ មហាសាំង ស្រុក ភ្នំស្រួច ខេត្ត កំពង់ស្ពឺ ។